# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ   សាសនា   ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រាមួយ .-**

មាត្រា២និងមាត្រា៩ នៃអនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ត្រូវបានធ្វើការកែសម្រួល ដូចតទៅ៖

**មាត្រា២ .- ថ្មី**

**គ.ម.ច.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រី | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |

- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអធិការកិច្ច ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- តំណាងកាកបាទក្រហមកម្ពុជា ១រូប សមាជិក
- តំណាងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ១រូប សមាជិក
- តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១រូប សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា ១រូប សមាជិក
- តំណាងស្ថាប័នឬអង្គភាពពាក់ព័ន្ធ មួយចំនួន សមាជិក
- ប្រធាននាយកដ្ឋានមនុស្សចាស់និងអតីតយុទ្ធជន សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ម.ច.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៩ ._ ថ្មី**

**គ.ម.ច.** មាននាយកដ្ឋានមនុស្សចាស់និងអតីតយុទ្ធជន នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាលេខាធិការដ្ឋានសម្រាប់គាំទ្រដល់ការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

ប្រធាននាយកដ្ឋានមនុស្សចាស់និងអតីតយុទ្ធជន នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធានលេខាធិការដ្ឋាន **គ.ម.ច.**។ ប្រធានលេខាធិការដ្ឋាននៃ **គ.ម.ច.** មានសិទ្ធិប្រើមន្ត្រីនាយកដ្ឋានមនុស្សចាស់និងអតីតយុទ្ធជន ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ក្នុងករណីចាំបាច់ លេខាធិការដ្ឋាននៃ **គ.ម.ច.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យជួយការងាររបស់ខ្លួនក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់លេខាធិការដ្ឋាន **គ.ម.ច.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រាពីរ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ជា សុមេធី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាពីរ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ